**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

**សារលិខិតថ្វាយព្រះពរ**

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ៦៨ យាងចូល ៦៩ ព្រះវស្សា**

**ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត !**

ក្នុងឱកាសដ៏នក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់ ៦៨ យាងចូល ៦៩ ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១នេះ ទូលព្រះបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមទូលព្រះបង្គំនិងភរិយា សូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត ក្រាបបង្គំទូលថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ សិរីមង្គល មហាប្រសើរ ថ្វាយ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** សូមទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលរឹងមាំ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់កូនចៅប្រជារាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

នាឱកាសនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមសម្តែងថ្វាយនូវកតញ្ញូកតវេទិតាធម៌យ៉ាងស្មោះស្ម័គ្របំផុត ចំពោះព្រះមហាករុណាធិគុណរបស់ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលជានិច្ចកាលទ្រង់តែងបំពេញព្រះរាជបូជនីយកិច្ចដ៏ខ្ជាប់ខ្ជួន សព្វព្រះរាជហឫទ័យប្រោសប្រទាននូវព្រះព្រហ្មវិហារធម៌ ព្រមទាំងបានប្រោសព្រះរាជទាននូវព្រះរាជទ្រព្យយ៉ាងច្រើនជួយដល់ប្រជារាស្ត្រទូទៅ និងតែងយកព្រះរាជហឫទ័យទុកដាក់ជាទីបំផុតរាល់ព្រះរាជកិច្ចសង្គម នាំមកនូវសុខសន្តិភាព និងភាពសុខដុមរមនាសម្បូរសប្បាយ ថ្កុំថ្កើងរុងរឿងជូនប្រជារាស្ត្រទូទាំងប្រទេស។

ជាថ្មីម្តងទៀត ក្នុងឱកាសដ៏មហាជ័យមង្គលនេះ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមលំឱនកាយវាចាចិត្តបួងសួង ចំពោះគុណបុណ្យព្រះរតនត្រ័យ មានទេវតាឆ្នាំថ្មី ទេវតារក្សាព្រះមហាស្វេតច្ឆត្រ ព្រមទាំងព្រះរាជតេជបារមី នៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ ប្រោសព្រះរាជទានប្រសិទ្ធិពរជ័យ មហាប្រសើរ ថ្វាយ **ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង** ប្រកបដោយព្រះបរមសុខ មានព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់ត្រជុំដល់ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ព្រមទាំងប្រជារាស្ត្រខ្មែរអស់កាលជានិច្ចនិរន្តរ៍តរៀងទៅ។

សូម**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈទ្រង់ព្រះមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

ថ្ងៃសុក្រ ៣កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកនឹមិត្រ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ : ០២៣ ៨៨៣ ២៧៨ អ៊ីមែល : generalsec@mod.gov.kh